# ស្ថានទូតជប៉ុនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

## សុន្ទរកថារបស់ឯកឧត្តម ម៉ាសាហ៊ិមី គូរ៉ូគី
## ឯកអគ្គរាជទូត វិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុន
## ប្រចាំព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងពិធីសម្ពោធបើកការដ្ឋានគំរោងផ្លាស់ប្តូរ
## និង ពង្រីកបណ្តាញចែកចាយទឹកស្អាតនៅតាមក្រុងនានារបស់ខេត្ត

ថ្ងៃទី 19 ខែកក្កដា ២០១២

- សូមគោរព **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- សូមគោរព **ឯកឧត្តមអភិបាលរង** ខេត្តពោធិសាត់ ខេត្តបាត់ដំបង និង ខេត្តព្រះសីហនុ
- សូមគោរពឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស លោកស្រី អស់លោក

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានមកចូលរួមពិធីសម្ពោធបើកការដ្ឋាននៅថ្ងៃនេះ សំរាប់ “គំរោងផ្លាស់ប្តូរ និងពង្រីកបណ្តាញចែកចាយទឹកស្អាតនៅក្រុងពោធិសាត់ បាត់ដំបង និង ក្រុងព្រះសីហនុ” ។

ជាបឋម ខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធមិដ៏ជ្រាលជ្រៅចំពោះ **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តមនៅក្នុងពិធីនេះ ។

ថ្ងៃនេះ ខ្ញុំមានសេចក្តីរីករាយដើម្បីធ្វើជាសាក្សីនៃការចាប់ផ្តើមគំរោងផ្គត់ផ្គង់ទឹកស្អាត ដែលនឹងរួមចំណែកដល់សុខុមាលភាពរបស់ប្រជាជននៅក្រុងចំនួនបី គឺក្រុងពោធិសាត់ បាត់ដំបង និង ក្រុងព្រះសីហនុ ។

ការទទួលបានទឹកស្អាតដើម្បីប្រើប្រាស់គឺជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៏សហសវត្សរ៏នានា ដែលរួមចំណែកដល់ការកែលំអធ្វើអោយប្រសើរឡើងនូវស្ថានភាពជីវភាពរស់នៅ និងសុខភាព និងការកាត់បន្ថយ

ភាពក្រីក្ររបស់ប្រជាជន។ ដោយហេតុនោះប្រទេសជប៉ុនបាន និងកំពុងផ្តល់ជំនួយយ៉ាងសំខាន់សំរាប់ការកែលំអប្រពន្ធ័ផ្គត់ផ្គង់ទឹកស្អាតនៅព្រះរាជាណាចក្រកម្ពុជាចាប់តាំងពីទសវត្សរ៍ឆ្នាំ 1990 មក ។

រដ្ឋាភិបាលជប៉ុនបាន និងកំពុងផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួនសំរាប់គំរោងផ្គត់ផ្គង់ទឹកស្អាតនៅតាមទីក្រុងធំៗ ដូចជានៅទីក្រុងភ្នំពេញ និងទីក្រុងសៀមរាបដែលចំនួនប្រជាជនកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស ក៏ដូចជាការផ្គត់ផ្គង់ទឹកស្អាតជនបទនៅតាមភូមិនានានៅក្នុងខេត្តកំពង់ចាមជាដើម ។ ទាក់ទងទៅនឹងស្ថានភាពផ្គត់ផ្គង់ទឹកនៅតាមក្រុងនានារបស់ខេត្ត ការទទួលបានទឹកស្អាតដើម្បីប្រើប្រាស់នៅតែមានក៏រិតទាបនៅឡើយ ដោយសារភាពចាស់ទ្រុឌទ្រោមនៃរោងចក្រផលិតទឹក និងបំពង់ចែកចាយទឹកដែលចាស់ និងមិនគ្រប់គ្រាន់ ។

រដ្ឋាភិបាលជប៉ុនបានផ្តល់ជំនួយឥតសំណងរបស់ខ្លួនចំនួន J¥2.760.000.000 ( ពីរកោដិប្រាំពីររយហុកសិបលានយ៉េន) ប្រហែលស្មើនឹង USD34.000.000 (សាមសិបបួនលានដុល្លារ៍អាមេរិច) សំរាប់គំរោងនេះដើម្បីផ្លាស់ប្តូរបណ្តាញចាស់ និងពង្រីកបណ្តាញចែកចាយទឹកស្អាតថ្មីនៅក្រុងពោធិសាត់ បាត់ដំបង និង ក្រុងព្រះសីហនុ ។ គំរោងនេះនឹងជួយបង្កើនអោយបានច្រើនបំផុតនូវចំនួនប្រជាជនដែលអាចទទួលបានការផ្គត់ផ្គង់ទឹកស្អាត ដែលមានសុវត្ថិភាពនៅក្នុងក្រុងទាំងបីនេះហើយនឹងកាត់បន្ថយការឆ្លងជម្ងឺនានាដែលកើតចេញពីការប្រើប្រាស់ទឹកមិនស្អាត។

ខ្ញុំក៏រំពឹងផងដែរថាបំពង់ចែកចាយទឹកថ្មីដែលនឹងបំពាក់ជូននេះនឹងត្រូវបានថែទាំយ៉ាងល្អដោយមន្ត្រីអាជ្ញាធរផ្គត់ផ្គង់ទឹកមូលដ្ឋានដែលទទួលបានការបណ្តុះបណ្តាលផ្នែកបច្ចេកទេសពីគំរោងសហប្រតិបត្តិការបច្ចេកទេសរបស់ជប៉ុន ។

ខ្ញុំសង្ឃឹមថាគំរោងនេះ ដែលគ្រោងនឹងបញ្ចប់នៅខែមិថុនា ឆ្នាំ 2013 ខាងមុខនេះ នឹងត្រូវបានអនុវត្តន៏ដោយរលូន និងដោយជោគជ័យ ហើយដែលនឹងរួមចំណែកដល់ការកែលំអធ្វើអោយប្រសើរឡើងនូវស្ថានភាពជីវភាពរស់នៅរបស់ប្រជាជននៅក្នុងក្រុងទាំងនេះ ។

ចុងក្រោយនេះ ខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការពីសំណាក់ប្រជាជន និងរដ្ឋាភិបាលជប៉ុននេះ នឹងជួយពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងមិត្តភាពដ៏យូរអង្វែងរវាងប្រទេសជប៉ុន និង ព្រះរាជាណាចក្រកម្ពុជា ។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោក-អ្នក ។